# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..៩១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សមាជិកជ្រើសតាំង និងសមាសភាពការិយាល័យប្រតិបត្តិ សម្រាប់សភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ អាណត្តិទី១ លើកទី២

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការបង្កើត សភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ

- បានឃើញកំណត់ហេតុ ស្តីពីលទ្ធផល នៃការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១១
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១:** ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺចំនួន ១៥ រូប សម្រាប់អាណត្តិទី១ លើកទី២ ដូចខាងក្រោម៖

១-ឧកញ៉ា **ឈាំ ស្រ៊ុន** ២-លោក **សៀង ទូច** ៣-លោក **ជៀម ភាក់**
៤-លោក **ខូ សេង** ៥-លោក **អ៊ូ ខៃត** ៦-លោក **ឡេង ម៉ូង**
៧-ឧកញ៉ា **អ៊ុន យុទ្ធី** ៨-លោក **សាន់ ម៉ៅ** ៩-លោក **ចាន់ សុជាតិ**
១០-លោក **អ៊ឹង ឈុនទ្រី** ១១-លោក **យ៉ោក សីហា** ១២-លោកស្រី **ភាំង ផល្លា**
១៣-លោក **ណៃ ឡេងអ៊ឹម** ១៤-លោក **សែម ចំរើន** ១៥-លោក **ទុំ ប៊ុនធឿន**

**មាត្រា២:** ទទួលស្គាល់ឧកញ៉ា **ឈាំ ស្រ៊ុន** ជាប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ។

**មាត្រា៣:** ទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិរបស់សភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-ឧកញ៉ា **ឈាំ ស្រ៊ុន** | ប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ស្ពឺ |
| ២-លោក **សៀង ទូច** | សមាជិក |
| ៣-លោក **ជៀម ភាក់** | សមាជិក |
| ៤-លោក **ខូ សេង** | សមាជិក |
| ៥-លោក **អ៊ូ ខៃត** | សមាជិក |
| ៦-លោក **ឡេង ម៉ូង** | សមាជិក |
| ៧-ឧកញ៉ា **អ៊ុន យុទ្ធី** | សមាជិក |
| ៨-លោក **សាន់ ម៉ៅ** | សមាជិក |
| ៩-លោក **ចាន់ សុជាតិ** | សមាជិក |
| ១០-លោក **អ៊ឹង ឈុនទ្រី** | សមាជិក |
| ១១-លោក **យ៉ោក សីហា** | សមាជិក |
| ១២-លោកស្រី **ភាំង ផល្លា** | សមាជិក |
| ១៣-លោក **ណៃ ឡេងអ៊ឹម** | សមាជិក |
| ១៤-លោក **សែម ចំរើន** | សមាជិក |
| ១៥-លោក **ទុំ ប៊ុនធឿន** | សមាជិក |

**មាត្រា៤:** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពង់ស្ពឺ ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន

ដូចមានចែងក្នុងមាត្រា១ មាត្រា២ និងមាត្រា៣ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ[illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
ដើម្បីសុំចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ